**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០៣ ករណីថ្មីទៀត ជាបុរសជនជាតិខ្មែរដែលវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី និង ០១ ករណីថ្មី ជាបុរសជនជាតិម៉ាឡេស៊ី វិជ្ជមានវីរុសកូវីដ១៩

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាវេលាយប់ម៉ោង១៩:៣០នាទី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ បានបង្ហាញថា សំណាកវត្ថុវិភាគរបស់បុរសចំនួន ០៤នាក់ វិជ្ជមានវីរុសកូវីដ១៩ ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

**១. នៅខេត្តកំពង់ចាម៖ ០១ ករណី ជាជនជាតិម៉ាឡេស៊ី**

- បុរសអាយុ ៣៩ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩ ស្នាក់នៅបណ្ដោះអាសន្ននៅនគរបាន ស្រុកកងមាស ជាអ្នកមកពីប្រទេសម៉ាឡេស៊ី ធ្វើការងារផ្សព្វផ្សាយសាសនានៅតាមខេត្ត ដែលនៅពេលនេះកំពុងដាក់នៅដាច់ដោយឡែកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។

**២. នៅរាជធានីភ្នំពេញ៖ ០១ ករណី ជាជនជាតិខ្មែរ**

- បុរសអាយុ ៣៣ឆ្នាំ នៅច្រាំងចម្រេះ២ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលនឹងយកមកដាក់ឲ្យនៅព្យាបាលក្នុងមណ្ឌលសុខភាពចាក់អង្រែ។ បុរសនេះ មិនបានទៅប្រទេសម៉ាឡេស៊ីទេ ហើយតាមការសាកសួរ ជាករណីចម្លងពីការនៅជិតស្និទ្ធនិងចាប់ដៃជាមួយបុរសដែលវិជ្ជមានវីរុសកូវីដ១៩ ដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

**៣. នៅខេត្តបាត់ដំបង៖ ០២ ករណី ជាជនជាតិខ្មែរ**

- បុរសអាយុ ៤៨ឆ្នាំ នៅភូមិសួគ៌ី២ សង្កាត់រតនៈ ក្រុងបាត់ដំបង មានតេស្តវិជ្ជមានវីរុសកូវីដ១៩។
- បុរសអាយុ ៣៨ឆ្នាំ នៅភូមិពោធិ២ ឃុំតាគ្រាម ស្រុកម៉ោងឫស្សី មានតេស្តវិជ្ជមានវីរុសកូវីដ១៩។

សម្គាល់៖ បុរសទាំង០២នាក់នេះ ត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តបាត់ដំបង ហើយជាអ្នកដែលបានវិលត្រឡប់មកពីពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

**៤. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង២១:០០ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៥១ នាក់ (ស្រី ០៤នាក់ ប្រុស ៤៧នាក់) ដែលក្នុងនោះ មានជនជាតិ ចិន ១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ៣នាក់ កាណាដា ១នាក់ បែលហ្ស៊ិក ១នាក់ បារាំង ២នាក់ (ក្នុងនេះមានកូនប្រុសបង្កើតអាយុ០៤ខែ) ម៉ាឡេស៊ី ១២នាក់ ខ្មែរ ៣១នាក់ (ក្នុងនេះអ្នកដែលវិលត្រឡប់មកពីពិធីសាសនានៅប្រទេសម៉ា

ម៉ាឡេស៊ី ២៥នាក់ និងមានស្ត្រី០២នាក់ (មិនបានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី) ជាភរិយាឆ្លងពីស្វាមី ព្រមទាំងមានបុរសម្នាក់មិនដែលទៅក្រៅប្រទេសតែមានប៉ះពាល់ជិតស្និទ្ធ និងបានចាប់ដៃជាមួយបុគ្គលដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០